ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

**ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៩**

# សេចក្តីប្រកាសព័ត៌មាន
## ទស្សនិកជនជាង ២០.០០០ នាក់បានចូលរួមក្នុងសវនាការលើរឿងក្តី ឌុច

នៅថ្ងៃពុធ ទី២៦ ខែសីហា ឆ្នាំ២០០៩ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានឈានដល់កំណត់ត្រាថ្មីមួយ ខណៈចំនួនទស្សនិកជនដែលមានវត្តមានក្នុងសវនាការលើសំណុំរឿង ០០១ ប្រឆាំងនឹង កាំង ហ្គេកអ៊ាវ ហៅ ឌុច បានកើនលើសពីចំនួន ២០.០០០ នាក់។

មកទល់នឹងថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៩ ទស្សនិកជនចំនួន ២០.២៥០ នាក់ បានមកចូលរួមក្នុងសវនាការលើរឿងក្តី ឌុច ចាប់តាំងពីពេលចាប់ផ្តើមបើកសវនាការនៅថ្ងៃទី៣០ ខែមីនា កន្លងមក។ តួលេខនេះធ្វើឱ្យចំនួនទស្សនិកជនជាមធ្យមក្នុងមួយថ្ងៃមានចំនួន ៣១១ នាក់។ ចំនួនទស្សនិកជនសរុប រួមមានទស្សនិកជនមកពីខេត្តចំនួន ១១ នៃប្រទេសកម្ពុជា (កណ្តាល, កំពង់ចាម, កំពង់ស្ពឺ, កំពង់ធំ, ភ្នំពេញ, កំពង់ឆ្នាំង, ក្រចេះ, សៀមរាប, ពោធិ៍សាត់, តាកែវ និងកំពត)។ បន្ថែមលើនេះទៀត ទស្សនិកជនមកពីប្រទេសចំនួន ២២ ផ្សេងទៀត ក៏បានចូលរួមក្នុងកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការនេះដែរ។

ក្នុងអំឡុងប៉ុន្មានខែថ្មីៗនេះ ផ្នែកកិច្ចការសាធារណៈបានពង្រឹងកិច្ចខិតខំប្រឹងប្រែងទាំងឡាយ ដើម្បីបង្កើនសកម្មភាពផ្សព្វផ្សាយនានា និងចំនួនវត្តមានទស្សនិកមកកាន់តុលាការនេះ។ ដោយសារគោលដៅផ្សព្វផ្សាយដ៏មានប្រសិទ្ធភាពធ្វើឡើងតាមរយៈសារព័ត៌មាន ទូរទស្សន៍ និងវិទ្យុ នោះតុលាការមានលទ្ធភាពផ្តល់ព័ត៌មានជូនអ្នកមកទស្សនាបានកាន់តែទូលំទូលាយ ក្នុងការមកចូលរួមស្តាប់ការជំនុំជម្រះ។ អ.វ.ត.ក បានផ្តល់ជូននូវការដឹកជញ្ជូនតាមរថយន្តក្រុងដោយឥតគិតថ្លៃ មកពីបណ្តាខេត្ត សម្រាប់ក្រុមមនុស្សដែលមានចំនួន ៣០

នាក់ ឬជាង ៣០នាក់ ដែលបានសម្ដែងចំណាប់អារម្មណ៍នៅក្នុងការចូលរួមស្ដាប់សវនាការជំនុំជម្រះរឿងក្ដី ឌុច។

ការជំនុំជម្រះលើរឿងក្ដី ឌុច អស់រយៈពេលប្រាំខែកន្លងមកហើយនេះ នៅតែមានការចាប់អារម្មណ៍ជាបន្តបន្ទាប់ក្នុងការមកទស្សនាតុលាការនេះ។ ថ្ងៃបំពេញការងាររបស់តុលាការគិតរហូតមកដល់ថ្ងៃទី ១៧ ខែកញ្ញានេះ គឺត្រូវបានកក់ទុកស្ទើរតែគ្រប់ថ្ងៃការងារអស់ទៅហើយ ដោយមានការសុំឲ្យរៀបចំបម្រុងទុកជាមុនពីសំណាក់ទស្សកិកជនថ្មីៗទៀត។

| **កាលបរិច្ឆេទសវនាការ (ប្រចាំសប្ដាហ៍)** | **ទស្សនិកជនសរុប (ប្រចាំសប្ដាហ៍)** |
|---|---|
| ៣០/០៣/០៩ - ០១/០៤/០៩ | ១.១៧៦ នាក់ |
| ០៦/០៤/០៩ - ០៩/០៤/០៩ | ៦២៣ នាក់ |
| ២០/០៤/០៩ - ២៣/០៤/០៩ | ៦៤២ នាក់ |
| ២៧/០៤/០៩ - ៣០/០៤/០៩ | ៧៤២ នាក់ |
| ១៨/០៥/០៩ - ២១/០៥/០៩ | ៥៧៥ នាក់ |
| ២៥/០៥/០៩ - ២៨/០៥/០៩ | ៥៦០ នាក់ |
| ០៨/០៦/០៩ - ១០/០៦/០៩ | ៤១៥ នាក់ |
| ១៥/០៦/០៩ - ១៧/០៦/០៩ | ៦២១ នាក់ |
| ២២/០៦/០៩ - ២៥/០៦/០៩ | ៨៦០ នាក់ |
| ២៩/០៦/០៩ - ០២/០៧/០៩ | ១.៨៩៩ នាក់ |
| ០៦/០៧/០៩ - ០៩/០៧/០៩ | ១.៥៥៣ នាក់ |
| ១៣/០៧/០៩ - ១៦/០៧/០៩ | ១.៥០៤ នាក់ |
| ២០/០៧/០៩ - ២២/០៧/០៩ | ១.៣០១ នាក់ |
| ២៧/០៧/០៩ - ២៨/០៧/០៩ | ១.០៩៤ នាក់ |
| ០៣/០៨/០៩ - ០៦/០៨/០៩ | ១.៦៨៧ នាក់ |
| ១០/០៨/០៩ - ១២/០៨/០៩ | ១.៤៦៣ នាក់ |
| ១៧/០៨/០៩ - ២០/០៨/០៩ | ២.១៧៦ នាក់ |
| ២៤/០៨/០៩ - ២៦/០៨/០៩ | ១.៣៥៩ នាក់ |

| | |
|---|---|
| **ចំនួនសរុបគិតមកទល់នឹងថ្ងៃពុធ ទី២៦ ខែ សីហា ឆ្នាំ២០០៩** | **២០.២៥០ នាក់** |

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោក រាជ សម្បត្តិ
ផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក
ទូរសព្ទដៃលេខ +៨៥៥ ១២ ៤៨៨ ១៥៦
Fax: +855-23 219 841
អ៊ីមែលៈ reach.sambath@eccc.gov.kh

លោក ឌីម សុវណ្ណារ៉ុំ
មន្ត្រីទទួលបន្ទុកព័ត៌មាននៃ អ.វ.ត.ក
ទូរសព្ទដៃលេខ +៨៥៥ ១២ ៤៨៨ ០៩៤
ទូរសព្ទលើតុ +៨៥៥ (០) ២៣ ២១៩ ៨១៤
អ៊ីមែលៈ dim.sovannarom@eccc.gov.kh

លោក Lars Olsen
មន្ត្រីផ្នែកទំនាក់ទំនងច្បាប់នៃ អ.វ.ត.ក
ទូរសព្ទដៃលេខ +៨៥៥ (០) ១២ ៤៨៨ ០២៣
ទូរសព្ទលើតុ +៨៥៥ (០) ២៣ ២១៩ ៨១៤ ext. ៦១៦៩
អ៊ីមែលៈ olsenl@un.org

លោកស្រី Yuko Maeda
មន្ត្រីផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក
ទូរសព្ទដៃលេខ +៨៥៥-១២ ៤៨៨ ៣១៩
ទូរសព្ទលើតុ +៨៥៥ ២៣ ២១៩ ៨១៤ ext. ៦១៣៩
អ៊ីមែលៈ maeday@un.org